## កន្លែងទាក់ទងសំខាន់ៗ៖

**ការិយាល័យរបស់មេធាវីមណ្ឌល (District Attorney's Office)**
142 Federal Street
Portland, ME 04101
ទូរស័ព្ទ៖ 207-871-8384
ទូរសារ៖ 207-775-3561
www.cumberlandcounty.org

**ការិយាល័យក្រុងវ៉េសបាស (West Bath Office)**
147 New Meadows Road
Bath, ME 04530
ទូរស័ព្ទ៖ 207-443-5104

**ក្រុមប្រឹក្សាផ្នែកការសងការបង់ខាងរបស់ជនរងគ្រោះ៖**
**(Victim's Compensation Board)**
Department of the Attorney General
6 State House Station
Augusta, ME 04333-0006
ទូរស័ព្ទ៖ 207-624-7882

**កិច្ចបំរើផ្នែកវិបត្តិក្នុងគ្រួសារ (Family Crisis Services)**
ទូរស័ព្ទប្រចាំការ៖ 207-874-1973
ឬ 800-537-6066
ទីចាត់ការ៖ 207-767-4952
FamilyCrisis@FamilyCrisis.org

**កិច្ចបំរើមុនពេលកាត់ក្តីនៃរដ្ឋមេន (Maine Pretrial Services)**
175 Lancaster Street, Suite 305
Portland, ME 04101
207-774-1501
800-734-1501
ទូរសារ៖ 207-874-0218
Mepretrial@aol.com

**ការបំរើផ្នែកឆ្លើយតបនិងចាប់បង្ខំរំលោភ (Sexual Assault Response Services)**
PO Box 1371
Portland, ME 04104
លេខប្រចាំការ៖ 800-313-9900
207-774-3613 (Greater Portland)

**ក្រសួងបំរើសង្គមបេស់រដ្ឋមេន (Maine Department of Human Services)**
ការទទួលយកនៃក្រសួងការពារក្មេង
800-452-1999

**ក្រសួងពន្ធនាគារនៃរដ្ឋមេន (Maine Department of Correction)**
ការបំរើជនរងគ្រោះ
111 State House Station
Augusta, ME 04333
800-968-6909
www.state.me.us.org/corrections/

**មន្ទីរឃុំឃាំងរបស់ខោនទីឃឹមបឺលែន្ត (Cumberland County Jail)**
50 County Way
Portland, ME 04101
774-5939
www.cumberlandcounty.org

មេធាវីមណ្ឌលនៃខោនទីឃឹមបឺលែន្ត
ការិយាល័យរបស់មេធាវីមណ្ឌល

# សេចក្តីណែនាំអំពីប្រព័ន្ធនៃក្រសួងយុត្តិធម៏ផ្នែកបទឧក្រិដ្ឋសំរាប់ជនរងគ្រោះនិងសាក្សី



ស្ទេហ្វានី អែនដឺសុន (Stephanie Anderson)
**មេធាវីមណ្ឌលនៃខោនទីឃឹមបឺលែន្ត**

## បេសកកម្មរបស់យើង

*“មេធាវីមណ្ឌលធ្វើការនាំរឿងក្តីដោយភ្លាមៗ ប្រសិទ្ធិភាពនិងអាណិតអាសូរចំពោះសំណុំរឿងទាំងអស់ដែលគាត់ចោទប្រកាន់ក្នុងបញ្ហាការពាររដ្ឋធម្មនុញ្ញនិងសិទ្ធិស្របច្បាប់របស់ជនដែលត្រូវគេចោទប្រកាន់ គាំទ្រជួយជាប្រយោជន៏ដល់ជនរងគ្រោះ គោរពក្រសួងមានសមត្ថកិច្ច បង្កើនសុវត្ថិភាពសាធារណៈ ហើយនិងកាន់កាប់ដោយមានការទទួលខុសត្រូវនូវធនធានសាធារណៈ ។”*

**ទូរស័ព្ទ៖** 207-871-8384

# ការិយាល័យរបស់មេធាវីមណ្ឌល

## សេចក្តីផ្តើម

បើអ្នកជាជនរងគ្រោះ ឬមានពត៏មានអំពីបទឧក្រិដ្ឋមួយយើងត្រូវការអ្នកឲ្យជួយយើងដើម្បីផ្តន្ទាទោសជនប្រព្រិត្តល្មើសដោយធ្វើជាសាក្សី ។ យើងទទួលស្គាល់ថាអ្នកត្រូវបានគេជំរុញទៅក្នុងដំណើរការនេះដោយមិនស្ម័គ្រចិត្ត ហើយវាអាចនាំឲ្យភាន់ច្រឡំ ហួសចិត្តនិងការបារម្ភ ។ វាអាចមានការតានតឹងស្មើគ្នានិងការចូលទាក់ទងរបស់អ្នក វាមានទំងន់លើសលប់ដោយជួយយើងបង្កើតបរិយាកាសមានសុវត្ថិភាពសំរាប់អ្នក គ្រួសាររបស់អ្នក និងអ្នកជិតខាងរបស់អ្នក ។

ដើម្បីធ្វើរឿងនេះឲ្យកាន់តែងាយស្រួលសំរាប់អ្នក យើងបានរៀបចំកូនសៀវភៅនេះ ។ កូនសៀវភៅនេះជាទិដ្ឋភាពទូទៅរបស់ការិយាល័យ និងប្រព័ន្ធតុលាការ ។ កូនសៀវភៅនេះប្រាប់អ្នកផងដែរអំពីសិទ្ធិនិងការទទួលខុសត្រូវផ្នែកច្បាប់របស់អ្នក ។

ជាបន្ថែម យើងនឹងធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបានដើម្បីជំរាបដំណឹងដល់អ្នកឆ្លើយនិងសំណួររបស់អ្នក ហើយនិងជួយអ្នកបន្តតាម ដំណើរការទៅទៀត ។ យើងចង់ឲ្យអ្នកមានអារម្មណ៍ដឹងដំណឹងទាំងអស់ ឮដំណឹងមានការគោរពនិងគិតគូរយ៉ាងល្អ ។ នៅចុងបញ្ចប់ យើងចង់ឲ្យអ្នកមានអារម្មណ៍ថាយុត្តិធម៏ត្រូវបានរកឃើញហើយអ្នកជាភាគដ៏សំខាន់នៅក្នុងរឿងនេះ ។ យើងចង់ឲ្យអ្នកមានអារម្មណ៍មានសុវត្ថិភាពនិងមានការទុកចិត្តនិងជំនឿលើប៉ូលីស ការិយាល័យនេះ ហើយនិងប្រព័ន្ធតុលាការនេះ ។ បើមានអ្វីមួយដែលយើងអាចធ្វើបានដើម្បីជួយអ្នកសូមមេត្តាប្រាប់ឲ្យយើងដឹង ។ សូមអរគុណជាពន្លឹកចំពោះជំនួយនិងកិច្ចរួមសហការរបស់អ្នក ។

ដោយរាប់អាន

**ស្ទេហ្វានី អែនដឺសុន** (Stephanie Anderson)
**មេធាវីមណ្ឌលនៃខោនទីឃឹមបឺលែន្ត** (Cumberland County District Attorney)

## មេធាវីមណ្ឌល

តាមច្បាប់ មេធាវីមណ្ឌលត្រូវបានតំរូវឲ្យធ្វើក្តីសំណុំរឿងបទឧក្រិដ្ឋទាំងអស់(លើកលែងតែឃាតកម្មដែលចាត់ចែងដោះស្រាយដោយអគ្គមេធាវី) ដែលកើតឡើងនៅក្នុងរង្វង់នៃតំបន់នេះ ។ រដ្ឋមេនត្រូវបានចែកជាតំបន់កាត់ក្តីប្រាំបីតំបន់ ។ ខោនទីឃឹមបឺលែន្តជាតំបន់លេខ2 ហើយដោយសារខោនទីឃឹមបឺលែន្តមានប្រជារាស្ត្រជាង 260,000 នាក់ វាមានតំបន់កាត់ក្តីមួយដាច់មុខតែឯង ។

មេធាវីមណ្ឌលទាំងអស់ត្រូវបានបោះឆ្នោតរើសដោយប្រជារាស្ត្រតាមតំបន់របស់គេនៅក្នុងកំឡុងនៃការបោះឆ្នោតរើសប្រមុខរដ្ឋដែរ ហើយមានអាណត្តិបួនឆ្នាំ។ លោកស្រី ស្ទេហ្វានី អែនដឺសុន ត្រូវបានជាប់ឆ្នោតក្នុងឆ្នាំ1990 ហើយត្រូវបានជាប់ឆ្នោតទៀតក្នុងឆ្នាំ1994 1998 និង2002 ។ តាមការតំរូវរបស់ច្បាប់ គាត់រស់នៅក្នុងខោនទីឃឹមបឺលែន្ត ។ គាត់ធំដឹងក្តីនៅក្រុងអ៊ីលីយោត (Eliot) ហើយបានរៀននៅមហាវិទ្យាល័យនិងសាលាច្បាប់នៅក្នុងរដ្ឋមេននេះ ។ លោកស្រី អែនដឺសុនបានទទួលសញ្ញាប័ត្រច្បាប់របស់គាត់ក្នុងឆ្នាំ1980 ហើយធ្លាប់បានអនុវត្តិច្បាប់ខាងបទឧក្រិដ្ឋតាំងពីនោះមក ។

## ការិយាល័យរបស់មេធាវីមណ្ឌល

យើងតាំងនៅក្នុងសាលាក្តីនៃខោនទីឃឹមបឺលែន្ត 142 Federal Street ក្នុងក្រុងផតឡែន្ត ។ យើងបើកធ្វើការបីថ្ងៃក្នុងមួយអាទិត្យនៅក្នុងក្រុងវ៉េសបាថ (West Bath) និងបីថ្ងៃក្នុងមួយខែនៅក្នុងប្រ៊ីជថុន (Bridgton) យើងមានគ្នា57នាក់ ហើយយើងរួមគ្នាទាំងអស់ផ្តល់ការពិសោធន៏ក្នុងច្បាប់ផ្នែកបទឧក្រិដ្ឋនិងប្រព័ន្ធតុលាការជាច្រើនសតវត្ស ។ យើងចាត់ចែងប្រហែលជាង 23000 សំណុំរឿងក្នុងមួយឆ្នាំ ។

ដើម្បីចាត់ចែងសំណុំរឿងឲ្យមានប្រសិទ្ធភាព ការិយាល័យនេះត្រូវបានចែកចេញជាបួនផ្នែក ។ ផ្នែកនិមួយៗមានអនុមេធាវីមណ្ឌល (Assistant District Attorneys -- ADAs) គេក៏ហៅផងដែរថាមេធាវីដើមចោទនិងបុគ្គលិកគាំទ្រ ។

<u>ផ្នែកបទមជ្ឈឹម(Misdemeanor Division)</u> ចាត់ចែងបទលហុនិងបទល្មើសថ្នាក់មជ្ឈឹមទាំងអស់លើកលែងតែសំណុំរឿងខាងអំពើឃោរឃៅក្នុងគ្រួសារនិងផ្នែកកុមារ ។ អនុមេធាវីមណ្ឌលនិមួយៗត្រូវបានចាត់ឲ្យទទួលរ៉ាប់រងក្រសួងប៉ូលីសមួយឬលើសពីមួយ ។ មេធាវីដើមចោទប្រាំនាក់ រួមជាមួយសិស្សអនុវត្តិខាងច្បាប់ប្រាំមួយនាក់ (សិស្សសាលាច្បាប់ឆ្នាំទីបី) ហើយនិងបុគ្គលិកគាំទ្រចាត់ចែងសំណុំរឿងប្រហែល ជាង 20000 ក្នុងមួយឆ្នាំ ។

<u>ផ្នែកបទឧក្រិដ្ឋ(Felony Division)</u> មេធាវីចាត់ចែងសំណុំរឿងបទឧក្រដ្ឋទាំងអស់ ។ សំណុំរឿងត្រូវបានចាត់ទៅឲ្យមេធាវីពិសេសនៅពេលដែលយើងចាប់ផ្តើមចូលទាក់ទងក្នុងការស៊ើបអង្កេតដោយមិនរើសអើងក្រសួងប៉ូលីសឡើយ ។ មេធាវីម្នាក់ៗចាត់ចែងប្រហែល 200 សំណុំរឿងក្នុងមួយឆ្នាំ ។

<u>ផ្នែកអំពើឃោរឃៅក្នុងគ្រួសារ(Domestic Violence Unit)</u> ចាត់ចែងសំណុំរឿងអំពើឃោរឃៅបទមជ្ឈឹមនិងបទឧក្រិដ្ឋ ។ អំពើឃោរឃៅក្នុងគ្រួសារ បានត្រូវគេហៅថា ”សត្រូវសាធារណៈលេខមួយ ”។ សំណុំរឿងទាំងនេះមានការប៉ះពាល់ទឹកចិត្តខ្លាំងណាស់ពីព្រោះជារឿយៗឧក្រិដ្ឋជនត្រូវជាប្តី ឬអតីតប្តី ឬជនសំខាន់ឯទៀតរបស់ជនរងគ្រោះ ។ យើងបង្កើតផ្នែកអំពើឃោរឃៅក្នុងគ្រួសារដើម្បីឲ្យករណីទាំងនេះកាន់តែមានការចាប់អារម្មណ៍ពីមេធាវីនិងអ្នកជំនួយជនរងគ្រោះដែលត្រូវបានហ្វឹកហាត់ជាពិសេសនិងបូជាចំណេះដើម្បីចាត់ចែងសំណុំរឿងទាំងនេះ ។ ផ្នែកនេះចាត់ចែងប្រហែល 900 -1000 សំណុំរឿងក្នុងមួយឆ្នាំ ។

<u>ផ្នែកកុមារនិងយុវជន(Juvenile Division)</u> ចាត់ចែងសំណុំរឿងទាំងអស់ដែលជាប់ទាក់ទងជនប្រព្រិត្តបទល្មើសដែលមានអាយុតិចជា18ឆ្នាំ ។ នៅទីនេះការផ្តោតអារម្មណ៍គឺនៅលើការកែលំអជនប្រព្រិត្តបទល្មើសឡើងវិញ ហេតុនេះហើយសំណុំរឿងទាំងអស់ត្រូវបានផ្តល់ការយកចិត្តទុកដាក់យ៉ាងលើសលុប ។ មេធាវីដើមចោទនិមួយៗធ្វើការជាមួយមេធាវីចុងចោទ ក្រសួងប្រូបេសិននិងក្រសួងឯទៀតដែលកំពុងជាប់ទាក់ទងជាមួយក្មេងនិមួយៗ ។ យើងព្យាយាមដើម្បីឲ្យចេញជាផែនការល្អបំផុតដែលអាចធ្វើបានសំរាប់ក្មេងនោះខណៈដែលពិចារណាការបារម្ភរបស់ជនរងគ្រោះនិងសុវត្ថិភាពរបស់សាធារណៈ ។ ខុសពីដំណើរការខាងតុលាការដែលទាក់ទងនិងមនុស្សធំ ដំណើរការដែលទាក់ទងនិងក្មេងត្រូវបានបិទមិនឲ្យឃើញជាសាធារណៈទេលើកលែងតែក្នុងករណីបទឧក្រិដ្ឋ ឬបើក្មេងនោះមានប្រវត្តិពិសេស។ អនុមេធាវីមណ្ឌលនិមួយៗ ចាត់ចែង 250 -300 សំណុំរឿងក្នុងមួយឆ្នាំ ។

# ដំណើរការកាត់ក្តីរបស់តុលាការ

## បទចោទប្រកាន់

យើងទទួលខុសត្រូវសំរាប់ការសំរេចថាតើជនម្នាក់គួរឬមិនគួរត្រូវគេចោទប្រកាន់ ហើយនិងតើបទចោទប្រកាន់នោះគួរជាអ្វី ។ យើងយោងលើការសំរេចរបស់យើងទៅលើពត៌មានដែលយើងទទួលពីប៉ូលីសដែលស៊ើបអង្កេតឧក្រិដ្ឋកម្មនោះ ។ ជួនកាលយើងផ្ញើសំណុំរឿងត្រឡប់ទៅឲ្យប៉ូលីសវិញដើម្បីសុំពត៌មានបន្ថែមទៀត។

នៅពេលដែលយើងសំរេចថាចោទប្រកាន់សំណុំរឿងមួយ បើសិនបទឧក្រិដ្ឋនោះជាបទមជ្ឈឹម យើងដាក់ពាក្យប្តឹងក្នុងតុលាការមណ្ឌលមួយ នៃតុលាការមណ្ឌលបី—ក្រុងប្រីដតុន ក្រុងវេសបាថ ឬក្រុងផតឡែន្ត—យោងទៅលើកន្លែងដែលគេបានធ្វើបទល្មើសនោះ ។ បើសិនបទល្មើសនោះជាបទឧក្រិដ្ឋ យើងជូនសំណុំរឿងទៅអគ្គគណៈវិនិច្ឆ័យដែលជាក្រុមមួយមានប្រជារាស្ត្រ 23 នាក់ដែលជួបជុំគ្នាមួយខែម្តង ចំនួនពីរបីថ្ងៃដើម្បីពិនិត្យមើលភស្តុតាងនិងកំណត់ថាតើសំណុំរឿងនេះគួរឬមិនគួរបញ្ជូនទៅមុខទៀត ។ បើអគ្គគណៈវិនិច្ឆ័យបោះឆ្នោតថា**ទេ** សំណុំរឿងនោះត្រូវគេបញ្ចប់ ។ បើគេបោះឆ្នោតថា**បាទ** បណ្តឹងចោទប្រកាន់មួយត្រូវបានដាក់ប្តឹងប្រឆាំងទល់និងចុងចោទនៅក្នុងតុលាការជាន់ខ្ពស់ក្នុងក្រុងផតឡែន្ត ។

## ជំនួយ

មួយរយៈពេលខ្លីបន្ទាប់ពីសំណុំរឿងមួយត្រូវបានចោទប្រកាន់ជនរងគ្រោះ?អ្នកនាំពាក្យរបស់សាក្សីនិងទាក់ទងអ្នក និងនៅចាំឆ្លើយនិងសំនួររបស់អ្នក ហើយនិងជួយអ្នកតាមរយៈដំណើរការនេះ ។ វាជាការសំខាន់ណាស់ដែលអ្នកប្រាប់ឲ្យយើងដឹងនូវការប្រែប្រួលណាមួយនៅក្នុងពត៌មានសំរាប់ទាក់ទងអ្នក ដូចជាទូរស័ព្ទនៅផ្ទះនិងនៅកន្លែងធ្វើការឬអាស័យដ្ឋានសំរាប់ផ្ញើសំបុត្រ ។ នៅពេលណាមួយក្តីនៅខណៈដែលសំណុំរឿងត្រូវបានព្យួរទុក មេធាវីរបស់ចុងចោទ ឬអ្នកស៊ើបអង្កេតរបស់អ្នកអាចព្យាយាមនិយាយជាមួយអ្នកបាន ។ វាជាការសំរេចគាត់ទេ បើអ្នកមិនចង់និយាយទេនោះ ។

## ប្រាក់បង់ធានាខ្លួន

នៅពេលជនម្នាក់ត្រូវបានចោទប្រកាន់ ធម្មតាគេកំណត់ចំនួនប្រាក់បង់ធានាខ្លួន។ ប្រាក់បង់ធានាខ្លួនអាចជាចំនួនប្រាក់និងឬល័ក្ខខ័ណ្ឌដែល គេរចនាឡើងដើម្បីអះអាងថាចុងចោទនិងត្រឡប់មកតុលាការវិញ ហើយនិងឲ្យជនរងគ្រោះមានអារម្មណ៍សុវត្ថិភាព ។ បើសិនចុងចោទមិនអាចមានប្រាក់តាមចំនួនទេឬអនុវត្តតាមល័ក្ខខ័ណ្ឌនៃការធានាខ្លួននេះទេ ពួកគេនៅជាប់ឃុំឃាំងរហូតដល់សំណុំរឿងរបស់ពួកគេត្រូវបានដោះស្រាយរួច ។

## ការបង្ហាញខ្លួនស្តាប់ការចោទប្រកាន់

បន្ទាប់ពីបណ្តឹងមួយត្រូវបានដាក់ប្តឹងនៅក្នុងតុលាការមណ្ឌល ឬបណ្តឹងចោទប្រកាន់មួយបានចេញដោយអគ្គគណៈវិនិច្ឆ័យ ចុងចោទបង្ហាញខ្លួនក្នុងតុលាការដើម្បីឲ្យគេប្រាប់អំពីបទចោទប្រកាន់និងដើម្បីឆ្លើយតប ។ នេះគេហៅថាការបង្ហាញខ្លួនស្តាប់ការចោទប្រកាន់ឬការបង្ហាញខ្លួនលើកដំបូង ។ ធម្មតាចុងចោទឆ្លើយថា "មិនមានកំហុសទេ"។ នៅពេលនេះហើយដែលការិយាល័យរបស់មេធាវីមណ្ឌលបញ្ចេញក្រដាសស្នាមអំពីភស្តុតាងទាំងអស់ដែលគេបានប្រមូលទុកដើម្បីប្រឆាំងទល់និងចុងចោទ ។ សំណុំក្រដាសនេះគេហៅថា "ការរកឃើញ"។

## សំណើរផ្លូវការ

បន្ទាប់ពីការបង្ហាញខ្លួនស្តាប់ការចោទប្រកាន់ គេឲ្យពេលចុងចោទ 21 ថ្ងៃដើម្បីដាក់ប្តឹង "សំណើរផ្លូវការ"។ សំណើរផ្លូវការភាគច្រើនបំផុត គេហៅថា "សំណើរផ្លូវការដើម្បីសង្កត់បញ្ជាក់" ដែលសុំឲ្យចៅក្រមបញ្ជាថាមេធាវីមណ្ឌលមិនអាចប្រើពត៌មានបែបនោះមកប្រឆាំងនិងចុងចោទទេ ។ សំណើរផ្លូវការអាចសុំឲ្យចៅក្រមបញ្ជាមេធាវីមណ្ឌលរកពត៌មានបន្ថែម ឬដើម្បីឲ្យរដ្ឋចាត់តាំងអ្នកស៊ើបអង្កេតឯកជនដើម្បីធ្វើការឲ្យចុងចោទ ។ សំណើរផ្លូវការទាំងអស់ត្រូវបានគិតគូររវាងមេធាវីឬដោយចៅក្រមបន្ទាប់ពីសវនាការមួយ ។ ជួនកាលសំណើរផ្លូវការអាចពន្យាពេលករណីនេះជាច្រើនអាទិត្យឬជាច្រើនខែទៀតផង ។ ការកាត់ទោសមិនអាចធ្វើបានទេរហូតទាល់តែសំណើរផ្លូវការទាំងអស់ត្រូវបានដោះស្រាយរួច ។

## កិច្ចព្រមព្រៀងសំរាប់ការសារភាព

ចំនួនភាគច្រើនបំផុតរបស់ចុងចោទសារភាពទទួលកំហុសដោយមិនបានទៅដល់ការកាត់ក្តី ។ ការសារភាពភាគច្រើនគឺជាលទ្ធផលនៃកិច្ចព្រមព្រៀងរវាងមេធាវីដើមចោទនិងមេធាវីរបស់ចុងចោទ ជាធម្មតាក្នុងការផ្តល់មកវិញជាថ្នូររបស់ការសារភាពទទួលទោសចំពោះការចោទប្រកាន់យើងនិងស្នើយោបល់ឲ្យមានការកាត់ក្តីជាក់លាក់។ ជួនកាលយើងនឹងលើកលែងការចោទប្រកាន់ដើម្បីប្តូរជាមួយការសារភាពចំពោះបទចោទប្រកាន់ឯទៀត ។ បើអ្នកជាជនរងគ្រោះ យើងនឹងធ្វើការព្យាយាមគ្រប់បែបយ៉ាងដើម្បីពិគ្រោះគ្នារកកិច្ចព្រមព្រៀងជាមួយអ្នកជាមុន ពីព្រោះយោបល់របស់អ្នកមានសារៈសំខាន់ណាស់ចំពោះយើង ។ នេះជាហេតុផលមួយទៀតថាតើហេតុអ្វីទើបអ្នកត្រូវតែប្រាប់ឲ្យយើងដឹងបើពត៌មានសំរាប់ទាក់ទងអ្នកកែប្រែ ។ បើអ្នកមិនចូលចិត្តកិច្ចព្រមព្រៀងសំរាប់ការសារភាពនោះទេ អ្នកមានសិទ្ធិប្រាប់ឲ្យចៅក្រមដឹង ។

កិច្ចព្រមព្រៀងសំរាប់ការសារភាពមានប្រយោជន៍ចំពោះជនរងគ្រោះពីព្រោះវាធានាអះអាងការជាប់ទោសចំពោះបទឧក្រិដ្ឋដោយមិនបាច់ដាក់ជនរងគ្រោះនិងសាក្សីឲ្យឆ្លងកាត់សភាពមិនស្រួលចិត្តនិងការប៉ះពាល់ជាខ្លាំងក្នុងការទៅកាន់ការកាត់ក្តី ហើយនិងមានការប្រថុយគ្រោះថ្នាក់ដែលអាចជាការរកឃើញថា "គ្មានកំហុស"។ វាក៏នឹងអនុញ្ញាតឲ្យយើងនាំសំណុំរឿងច្រើនថែមទៀតមកកាត់ទោសជាងពេលដែលយើងអាចធ្វើបានដោយគ្មានវា ។

## ដីកាកោះ

បើគ្មានកិច្ចព្រមព្រៀងសំរាប់ការសារភាពទេ រឿងនេះនឹងត្រូវបានកំណត់ពេលធ្វើការកាត់ក្តីមួយ ហើយយើងនិងផ្ញើដីការកោះមួយទៅឲ្យជនរងគ្រោះនិងសាក្សីទាំងអស់ ។ ដីការកោះគឺជាដីការបញ្ជារតំរង់ផ្លូវអ្នកឲ្យមកបង្ហាញខ្លួននៅតុលាការនៅថ្ងៃជាក់លាក់ឬមានពេលដើម្បីមកកាន់តុលាការក្នុងរយៈពេលជាក់លាក់មួយ ។ ការខកខានមិនធ្វើតាមដីការកោះមួយគឺជាបទឧក្រិដ្ឋ ។ បើមានហេតុផលខ្លះដែលអ្នកមិនអាចទៅបង្ហាញខ្លួនតាមពេលវេលាបញ្ជាក់នៅក្នុងដីការកោះទេ សូមមេត្តាទូរស័ព្ទទៅយើងនិងប្រាប់ឲ្យយើងដឹងហើយយើងនឹងធ្វើកិច្ចប្រឹងប្រែងគ្រប់យ៉ាងដើម្បីសំរបសំរួលតាមកម្មពេលវេលារបស់អ្នក ។ បើយើងមិនអាចកោះហៅអ្នកបានពីព្រោះអ្នកបានប្តូរលំនៅ ឬបើអ្នកមិនទៅបង្ហាញខ្លួននៅតុលាការទេ ចៅក្រមនឹងមុខជារំសាយសំណុំរឿងនេះចោល ។

## ការកាត់ក្តី

នៅក្នុងការកាត់ក្តីមួយ រដ្ឋមានបន្ទុកដើម្បីបញ្ជាក់ថាចុងចោទមានកំហុសដូចការចោទប្រកាន់ "ដោយគ្មានការសង្ស័យអ្វីឡើយ" ដែលមានន័យថាចៅក្រមឬគណៈវិនិច្ឆ័យត្រូវរកឃើញថាបទចោទប្រកាន់គឺ "ស្ទើរតែពិតទាំងស្រុងហើយ"។ នៅពេលកាត់ក្តីចុងចោទបានបង្ហាញមុខហើយ មេធាវីរបស់គាត់ត្រូវបានអនុញ្ញាតឲ្យសួរសំណួរពីសាក្សីទាំងអស់ ។ ការកាត់ក្តីទាំងអស់ (លើកលែងតែការកាត់ក្តីភាគច្រើនរបស់ក្មេង) បើកជាសាធារណៈដែលមានន័យថានរណាក៏អាចមើលបានដែរ ។ នៅក្នុងការកាត់ក្តីដោយគ្មានគណៈវិនិច្ឆ័យ បន្ទាប់ពីសាក្សីទាំងអស់ឆ្លើយនៅក្រោមសំបថរួចហើយ ចៅក្រមសំរេចថាតើចុងចោទមានកំហុសឬទេ ។ ក្នុងករណីកាត់ក្តីដោយមានគណៈវិនិច្ឆ័យដើម្បីឲ្យរកឃើញថាចុងចោទមានកំហុស ទាល់តែសមាជិកទាំងដប់ពីរនាក់របស់គណៈវិនិច្ឆ័យត្រូវតែយល់ព្រម ។

ចុងចោទមានសិទ្ធិប្តឹងតវ៉ាចំពោះការរកឃើញកំហុសនេះ ។ ការប្តឹងតវ៉ាអាចមានរយៈពេលរហូតដល់ពីរឆ្នាំ ហើយភាគច្រើនមិនមានជោគជ័យទេ ។ បើចុងចោទត្រូវគេរកឃើញថាគ្មានកំហុសទេរដ្ឋមិនអាចប្តឹងតវ៉ាបានទេហើយសំណុំរឿងនេះត្រូវបានបិទជារៀងរហូត ។

## ការកាត់ទោស

បន្ទាប់ពីចុងចោទសារភាពទទួលកំហុស ឬត្រូវបានរកឃើញថាមានកំហុសបន្ទាប់ពីការកាត់ក្តីរួចចៅក្រមកំណត់ថាតើទោសនិងត្រូវជាអ្វី ។ វាអាចប៉ុន្តែមិនកំរិតចំពោះ៖ជាប់គុក ជាប់ប្រូបេសិន បង់ពិន័យ ការបំរើសហគមន៍ ។ល។ ជនរងគ្រោះមានសិទ្ធិទៅស្តាប់នៅពេលកាត់ទោស ហើយអាចធ្វើដូច្នេះបានដោយថ្លែងការនៅនាសវនាការកាត់ទោស ឬសរសេរសេចក្តីថ្លែងមួយដែលអាចអានដោយមេធាវីដើមចោទបាន ។ បើអ្នកជាជនរងគ្រោះ យើងនឹងជំរាបអ្នកអំពីថ្ងៃទីឡើងកាត់ក្តី ហើយនិងជួយអ្នកប្រុងប្រៀបបើអ្នកប្រាថ្នាចង់ធ្វើសេចក្តីថ្លែងមួយ ។ បន្ទាប់ពីសវនាការមកពីមេធាវីដើមចោទ ជនរងគ្រោះនិងឬគ្រួសាររបស់ជនរងគ្រោះ ហើយនិងចុងចោទ ចៅក្រមនឹងប្រកាសការកាត់ទោសជាធម្មតានៅពេលនេះភ្លាមនិងនៅទីនោះ ។

បទឧក្រិដ្ឋត្រូវបានបែងចែកជាថ្នាក់ A ថ្នាក់ B ឬថ្នាក់ C ។ ការបំពានលើថ្នាក់ទទួលពិន័យយ៉ាងច្រើនបំផុតជាប់គុក 20 ឆ្នាំ(5 ឆ្នាំសំរាប់កាលៈទេសៈពិសេស) ថ្នាក់ B ជាប់គុក 10 ឆ្នាំ ហើយនិងថ្នាក់ C ជាប់គុកយ៉ាងច្រើនបំផុត 5 ឆ្នាំ ។ បទមជ្ឈឹមត្រូវបានគេចាត់ថាជាបទឧក្រិដ្ឋថ្នាក់ D និងថ្នាក់ E ហើយត្រូវគេដាក់ទោសយ៉ាងច្រើនបំផុតគឺជាប់ឃុំឃាំង ឬជាប់គុក 365 ថ្ងៃ ។ ការបង់ពិន័យ ប្រូបេសិន ឬការសងជំងឺចិត្តអាចត្រូវបានគេចេញដីកាបញ្ជាទៅតាមកំរិតណាមួយរបស់ជនប្រព្រិត្តឧក្រិដ្ឋកម្ម ។

ជនរងគ្រោះមានសិទ្ធិឲ្យគេប្រាប់អំពីការដោះលែងចុងចោទ ។ បើចុងចោទនៅក្នុងមន្ទីរឃុំឃាំងនៃខោនទីឃីមបឺលែន្ត សូមទូរស័ព្ទទៅមន្ទីរនោះ ។ បើចុងចោទជាប់គុក ចូរបំពេញពាក្យផ្ញើទៅអ្នកបន្ទាប់ពីកាត់ទោសរួចហើយបញ្ជូនវាទៅការិយាល័យនេះវិញ បើអ្នកប្រាថ្នាកែប្រែពត៌មានសំរាប់ទាក់ទងរបស់អ្នក សូមទូរស័ព្ទទៅមន្ទីរឃុំឃាំង ឬមួយបើចុងចោទជាប់គុក សូមទាក់ទងផ្នែកបំរើជនរងគ្រោះលេខនៅជាមួយក្រសួងពន្ធនាគារ ។ ការតំរូវឲ្យជំរាបដំណឹងចប់ដោយយោងទៅលើការដោះលែងចុងចោទឬលើសំណូមពរជាលាយល័កអក្សររបស់ជនរងគ្រោះ ។

## ការសងការបង់ខាតដល់ជនរងគ្រោះ

បើអ្នកបានបាត់បង់ខាងលុយកាក់ដោយសារលទ្ធផលផ្ទាល់នៃអំពើឧក្រិដ្ឋ យើងនិងសុំឲ្យតុលាការចេញបញ្ជាឲ្យចុងចោទសងលុយអ្នកជាភាគមួយនៃការកាត់ទោស ។ រឿងនេះគេហៅថាការសងការបង់ខាតវិញ ។ យើងនឹងផ្ញើពាក្យឲ្យអ្នកសំរាប់បំពេញអំពីការបាត់បង់របស់អ្នក ហើយយើងនឹងជួយបើអ្នកមានសំណួរអ្វីមួយអំពីពាក្យទាំងនោះ ។ ការសំរេចចេញដីការបញ្ជាឲ្យសងការបង់ខាតគឺស្រេចលើចៅក្រមដែល នឹងចេញដីកាបញ្ជាឲ្យសងការបង់ខាតនៅពេលដែលរកឃើញថាចុងចោទអាចមានលទ្ធភាពដើម្បីសងតែប៉ុណ្ណោះ ។

ជនរងគ្រោះអាចទាក់ទងក្រុមប្រឹក្សាខាងការសងការបង់ខាតដល់ជនរងគ្រោះដើម្បីសុំជំនួយផងដែរ ។ ក្រុមប្រឹក្សានេះមានមូលនិធិគាំទ្រ ដោយការទារលុយបន្ថែមពីការទារលុយពិន័យនៃបទឧក្រិដ្ឋទាំងអស់ ។ គោលបំណងនៃក្រុមប្រឹក្សានេះគឺដើម្បីសងជនរងគ្រោះនៃអំពើឧក្រិដ្ឋឃោរឃៅសំរាប់ការបាត់បង់វិញដោយមិនគិតថាតើចុងចោទត្រូវបានគេរកឃើញកំហុសជាក់ស្តែងឡើយ ។ ដើម្បីរកពត៌មាននិងជំនួយបន្ថែម អ្នកអាចទាក់ទងយើងឬក្រសួងអគ្គមេធាវីដែលត្រួតមើលពីលើក្រុមប្រឹក្សានេះ ។